JICA Cambodia Office - JICA カンボジア事務所
May 3 ·

[កិច្ចប្រជុំលើកទី៤របស់គណៈកម្មការសម្របសម្រួលនៃ គម្រោង Strings / The 4th Joint Coordination Committee Meeting (JCC), Strings Project]

កិច្ចប្រជុំលើកទី៤របស់គណៈកម្មការសម្របសម្រួល គម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា បានរៀបចំឡើងដោយក្រសួងសុខាភិបាល សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ជែកា នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រោមអធិបតីភាពរបស់ ឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល និងជានាយកគម្រោង។ កិច្ចប្រជុំនេះបានប្រព្រឹត្តឡើងក្នុងគោលបំណងដើម្បី (១)រាយការណ៍អំពីវឌ្ឍនភាពសកម្មភាពគម្រោងចាប់ពីខែតុលា ឆ្នាំ២០២៣ ដល់ខែ មេសា ឆ្នាំ២០២៤ (២)ពិភាក្សាលើសូចនាករនៃទំរង់ម៉ាទ្រិចគម្រោង(PDM) និង (៣)ផែនការសកម្មភាពរយៈពេល០៦ខែបន្ទាប់ ដែលក្នុងនោះរាប់បញ្ចូលទាំងការបណ្តុះបណ្តាលគ្រូបង្គោលផងដែរ។
កិច្ចប្រជុំនេះ ក៏មានការអញ្ជើញចូលរួមពី លោកស្រីសាស្ត្រាចារ្យជំនួយ ទូច សុខនាង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល និងជាប្រធានគ្រប់គ្រងគម្រោង លោកស្រី IKEMURA Ayano ជាលេខាទីពីរនៃស្ថានទូតជប៉ុន លោកស្រី MIURA Yoshiko តំណាងជាន់ខ្ពស់មកពីការិយាល័យជែកា ប្រចាំប្រទេសកម្ពុជា និងតំណាងផ្សេងៗមកពីក្រសួងសុខាភិបាល ទីស្នាក់ការកណ្តាលជែកា នៅប្រទេសជប៉ុន (តាមរយៈ Zoom) គណៈគិលានុបដ្ឋាកកម្ពុជា (CCN) មន្ទីរពេទ្យជាតិ មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត មន្ទីរពេទ្យបង្អែកខេត្ត និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគដែលមានទីតាំងក្នុងខេត្តសាកល្បង (បាត់ដំបង និងកំពង់ចាម)។

អត្ថបទ និងរូបថត៖ គម្រោង Strings

The 4th Joint Coordination Committee Meeting of Project for Strengthening In-Service Training System in Cambodia (JCC) was organized by the Ministry of Health (MOH) in collaboration with the Japan International Cooperation Agency (JICA) on 26th April 2024 at the Hotel Cambodiana, and was presided over by H.E. Prof. THIR Kruy, Secretary of State of the MOH, and Project Director. The purpose of this meeting was to (1) report on the progress of project activities from October 2023 to April 2024, (2) discuss the indicators of the project matrix (PDM) and (3) confirm the action plan for the next 6 months, which includes training of trainers (TOT).
The meeting was attended by Assistant Professor Touch Sokneang, Director of the Human Resource Development Department of the MOH, Project Manager, Ms. IKEMURA Ayano, Second Secretary of the Embassy of Japan, Ms. MIURA Yoshiko, Senior Representative from JICA Cambodia Office and other representatives from the MOH, JICA Headquarters in Japan (via Zoom), Cambodian Council of Nurses (CCN), National Hospitals, Administration Provincial Health Departments, Provincial Hospitals, and Regional Training Centers in pilot provinces (Battambang and Kampong Cham).

Article and photos Credited: Strings Project